# សេចក្ដីសំរេចលេខ ២១ សសរ.
## ស្ដីពីការបង្កើតគណៈកម្មការចំរុះដោះស្រាយ
## បញ្ហាជនអានាថា ក្នុងរាជធានីភ្នំពេញ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងសេចក្ដីសំរេចលេខ ២៣សសរ. ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតគណៈកម្មការចំរុះដោះស្រាយបញ្ហាជនអនាថាក្នុងរាជធានីភ្នំពេញ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

## សំរេច

**ប្រការ ១** : បង្កើតគណៈកម្មការចំរុះដោះស្រាយបញ្ហាជនអានាថា ក្នុងរាជធានីភ្នំពេញ ដែលមានសមាសភាពដូចតទៅ :

| | |
|---|---|
| ១- ឯកឧត្ដម រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា | ប្រធាន |
| ២- ឯកឧត្ដម រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣- ឯកឧត្ដម ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ | អនុប្រធាន |
| ៤- លោកតំណាងក្រសួងសុខាភិបាល | សមាជិក |
| ៥- លោក តំណាងក្រសួងអប់រំ យុវជន និង កីឡា | សមាជិក |
| ៦- លោក តំណាងក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ៧- លោក តំណាងក្រសួងកិច្ច ការនារី និងអតីតយុទ្ធជន | សមាជិក |
| ៨- លោក តំណាងក្រសួងពត៌មាន | សមាជិក |
| ៩- លោក តំណាងក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |

១០- លោក តំណាងគណៈកម្មាធិការសមាគមកាកបាទក្រហមកម្ពុជា សមាជិក

ប្រការ ២ : គណៈកម្មការនេះមានភារកិច្ច ប្រមូលជនអានាថាទាំងអស់ ក្នុងរាជធានីភ្នំពេញ ដើម្បីបញ្ជូនឲ្យទៅរស់នៅតាមបណ្តាខេត្តរបស់ខ្លួនវិញ ។

ក្នុងរយៈពេលប្រមូលផ្តុំ ត្រូវដោះស្រាយរកជំរកស្នាក់នៅបណ្តោះអាសន្ន ឧបត្ថម្ភស្បៀងអាហារ ព្យាបាលជម្ងឺ ធ្វើការអប់រំ ណែនាំឲ្យបានល្អ និងសម្របសម្រួល ព្រមទាំងទទួលបន្ទុកលើមធ្យោបាយដឹកជញ្ជូនជនទាំងនោះឲ្យបានដល់មូលដ្ឋាន ដែលជាគោលដៅរស់នៅអចិន្ត្រៃយ៍របស់គេ ។

ប្រការ ៣ : សមាជិកគណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។ គណៈកម្មការ នេះមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងនីតិសម្បទា ។

ប្រការ ៤ : គណៈកម្មការនេះមានសិទ្ធិតាំងគណៈកម្មការអចិន្ត្រៃយ៍ ដើម្បីអនុវត្តជាប់ជាប្រចាំសំដៅទប់ស្កាត់ជនអនាថា ក្នុងទីក្រុងទទួលបានលទ្ធផលល្អជារៀងរហូត ។

ប្រការ ៥ : សេចក្តីសំរេចទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៦ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងអតីតយុទ្ធជន រដ្ឋមន្ត្រី ក្រសួងសុខាភិបាល រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ រដ្ឋមន្ត្រីក្រសួង អភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ប្រធានគណៈកម្មាធិការសមាគមកាកបាទក្រហមកម្ពុជា និងបណ្តាក្រសួងស្ថាប័ន ដែលមានការពាក់ព័ន្ធ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

★★★

រាជធានីភ្នំពេញ,ថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៩៩

## សេចក្តីសំរេចលេខ ២២ សសរ.

## ស្តីពីការបង្កើតគណៈកម្មការ រៀបចំទិវាកីឡាជនពិការកម្ពុជា

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា